មជ្ឈមណ្ឌលឯកសារកម្ពុជា

PTI0077

សម្ភាសន៍ជាមួយឈ្មោះ សាយ រីម ភេទប្រុស អាយុ៥៣ឆ្នាំ

មុខងារជំនាន់ខ្មែរក្រហម «ទាហាន»

ស្រុកកំណើតនៅភូមិពាមរវារ ឃុំព្រាំងជួរ ស្រុកឪរ៉ាល់ ខេត្តកំពង់ស្ពឺ

រស់នៅភូមិដីក្រហម ឃុំអន្ទង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៥៣:៤៣

ទំព័រ ២១

វណ្ណៈ អីចឹងជាដំបូងខ្ញុំសូមណែនាំថាខ្ញុំមកពីណាសិនណាស

រីមៈ បាទ!ប្រាប់ឈ្មោះផង ។

វណ្ណៈ បាទ!ខ្ញុំឈ្មោះសុខ វណ្ណៈមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្ញុំមកនេះដើម្បីចង់ដឹងរឿងរ៉ាវដែលបងប្អូនយើងឆ្លងកាត់ជាច្រើនជំនាន់មកថាមានរឿងអីខ្លះ សុខទុក្ខយ៉ាងណាខ្លះ ។

រីមៈ បាទ!

វណ្ណៈ ចឹងចាំពូជួយនិយាយឲ្យពុ្ទៗបន្តិច ។

រីមៈ បាទ!

វណ្ណៈ អីចឹងបទសម្ភាសខ្ញុំជាមួយពូតើពូអនុញ្ញាតឲ្យខ្ញុំយកទៅចងក្រងជាសៀវភៅដើម្បីឲ្យកូនចៅជំនាន់ក្រោយបានដឹងបានយល់បានទេពូ?

រីមៈ ទេបើកន្លែងណាបានៗតែបើអត់បានពិបាកចងក្រងដែរព្រោះកន្លែងណានិយាយមានចូលមានចេញមានភ្លេចមានភ្លាំងចឹងទៅចឹងវាពិបាកវែងឆ្ងាយពិបាកនិយាយដែរ ហើយឯកសារអីក៏វាមិនបានពិតប្រាកដដែរ ។

វណ្ណៈ អត់អីទេពូបើកន្លែងយើងចាំយើងនិយាយទៅបើអត់ចាំក៏អត់អីដែរ ។

រីមៈ ទាល់តែនិយាយពីជីវិតខ្ញុំឆ្នាំណា ខែណាចឹងទៅបានវាត្រូវរឿងណាស?

វណ្ណៈ បាទ!ចាំខ្ញុំសួរតាមហ្នឹង តែសំខាន់ខ្ញុំចង់សុំបទសម្ភាសហ្នឹងទៅសរសេរជាសៀវភៅឲ្យក្មេងបានដឹងបានឮដូចជាសៀវភៅនេះអីបានទេពូ? អត់អីទេហ្អី?

រីមៈ ហ៊ឺ អត់ដែលជួបប្រទះដែរមិនដឹងយ៉ាងម៉េចដែរប៉ុន្តែវាជាការពិតចឹងណាស!

វណ្ណៈ៖ បាទ!តែគ្រាន់តែថាយើងយកទៅចងក្រងទុកជាឯកសារឲ្យក្មេងៗបានរៀនសូត្រណាស បានតើហ្អីពូ?

រីមៈ ទេ!បើកន្លែងណាអីខាងហ្នឹងជួយមើលផងណា ព្រោះមនុស្សយើងមានខុសមានត្រូវ ។

វណ្ណៈ៖ បាទមិនអីទេពូ ។

រីមៈ បាទ!កន្លែងណាខុសអីក្មួយឯងកុំយកអី ព្រោះគេយកតែការពិតហើយខ្ញុំតាកង៉ាកតាំងពីព្រឹកមកវាមិនពិតខ្លះដែរ ហើយណាមួយចាស់ហើយវាវង្វេងផង ។

វណ្ណៈ៖ មិនបាច់បារម្ភទេពូណាស! ព្រោះពត៌មានយើមិនមែនចេះតែចុះផ្តេសផ្តាសទេយើងចុះតែអ្វីដែលយើងបានឆ្លងកាត់អីចឹង ។ អីចឹងខ្ញុំអាចសម្ភាសជាមួយបានពូណាស?

រីមៈ បាទ!

វណ្ណៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

រីមៈ បាទ! ខ្ញុំឈ្មោះសាយ រីម ។

វណ្ណៈ សាយ រីម?

រីមៈ បាទ!

វណ្ណៈ៖ ពូអាយុប៉ុន្មានហើយ?

រីមៈ ៥៣ហើយ ។

វណ្ណៈ៖ តំណាលពូប្រធានភូមិដែរ ។ ប្រពន្ធពូឈ្មោះអី?

រីមៈ ឈ្មោះ ឈួន ម៉ៅ ។

វណ្ណៈ៖ ឈួនហ្អី?

រីមៈ បាទ!

វណ្ណៈ៖ គាត់អាយុប៉ុន្មាន?

រីមៈ អាយុប៉ុន្មានទេ សែហើយ ។

វណ្ណៈ៖ សែ សែសិប?

រីមៈ បាទ!

វណ្ណៈ៖ កូនចៅប៉ុន្មានហើយកូនពូ?

រីមៈ កូនបី ។

វណ្ណៈ៖ បីនាក់ទេ?

រីមៈ បាទ!

វណ្ណៈ៖ ស្រីប៉ុន្មាន?

រីមៈ ស្រីពីរ ។

វណ្ណៈ ឪពុករបស់ពូឈ្មោះអីដែរ?

រីមៈ ឈ្មោះប្រាក់ ។

វណ្ណៈ ឈ្មោះអីប្រាក់?

រីមៈ ឪខ្ញុំ មិនដឹងតាគាត់ឈ្មោះអីទេ ។

វណ្ណៈ អត់ដឹងទេ ចឹងឈ្មោះប្រាក់?

រីមៈ បាទ!

វណ្ណៈ ម្ដាយ?

រីមៈ ម្ដាយខ្ញុំឈ្មោះពុច ។

វណ្ណៈ ចុះត្រកូលគាត់ស្គាល់ដែរអត់?

រីមៈ អត់ ។

វណ្ណៈ ឈ្មោះអីអញ្ចឹង?

រីមៈ ពូច ពុច ។

វណ្ណៈ ចុះឪពុកម្ដាយពូសព្វថ្ងៃគាត់នៅរស់ឬយ៉ាងម៉េចដែរ?

រីមៈ អត់ទេ ស្លាប់តាំងពីជំនាន់បីឆ្នាំ ។

វណ្ណៈ ស្លាប់តាំងពីជំនាន់ខ្មែរក្រហមទាំងអស់គ្នាហ្អី?

រីមៈ បាទ!ឪស្លាប់មុនហ្នឹងទៀតតែម៉ែស្លាប់ជំនាន់ខ្មែរក្រហម ជំនាន់បីឆ្នាំយើងហ្នឹង ។

វណ្ណៈ ឪពុកស្លាប់ឆ្នាំណា? មុនរដ្ឋប្រហារ?

រីមៈ ប្រហែលហ្នឹងឯង ខ្ញុំអត់ស្គាល់មុខ ។

វណ្ណៈ ហ៊ឹ ចុះបងប្អូនបង្កើតពូប៉ុន្មាន?

រីមៈ ប្រាំពីរនាក់ឯណោះ តែស្លាប់អស់ហើយនៅសល់តែពីរទេ ។

វណ្ណៈ ស្លាប់ឥឡូវៗហ្នឹងទេ?

រីមៈ ស្លាប់តាំងពីជំនាន់បីឆ្នាំឯណោះបែកបាក់គ្នាតាំងពីនោះមកនៅតែពីរនាក់នេះទេ ។

វណ្ណៈ ពូកូនទីប៉ុន្មាន?

រីមៈ ខ្ញុំកូនទី១ ។

វណ្ណៈ កូនបងគេបង្អស់?

រីមៈ បាទ!

វណ្ណៈ ហ៊ឹ ម៉េចត្រូវបើបងគេហើយអត់ស្គាល់ឪពុកម៉េចបើមានកូនដល់ប្រាំពីរនាក់?

រីមៈ ចុះបើពីរដើណរដូចបានកូនតែពីរចឹងម៉ែខ្ញុំយកទៀត ។

វណ្ណៈ ហ្អស!ចឹងទេ? ចឹងបានខ្ញុំចង់ការងដែរ ។

រីមៈ ស្រុកកំណើតពូនៅភូមិអី?

វណ្ណៈ ស្រុកកំណើតនៅភូមិរវ៉ា ។

រីមៈ ភូមិពាមរវ៉ា ។

វណ្ណៈ ឃុំ?

រីមៈ ត្រពាំងជូរ ។

វណ្ណៈ ត្រពាំងជងហ្អី?

រីមៈ ត្រពាំងចូរ ។

វណ្ណៈ ស្រុក?

រីមៈ ស្រុកឱរ៉ាល់ ។

វណ្ណៈ ខេត្ត?

រីមៈ ខេត្តកំពង់ស្ពឺ ។

វណ្ណៈ ឥឡូវរដនៅភូមិអី?

រីមៈ ដីក្រហម ។

វណ្ណៈ ភូមិដីក្រហម ។ ឃុំ?

រីមៈ អន្ទង់រាប ។

វណ្ណៈ ស្រុក?

រីមៈ វ៉ាលវែង ។

វណ្ណៈ ខេត្តពោធិ៍សាត់ ។

រីម ៈ ចុះកាលពីតូចពូបានរៀនទេ?

វណ្ណៈ រៀនដល់ឆ្នាំ៧៣ ៧៤ ឈប់រៀនទៅរៀនបានមួយឆ្នាំ ។

រីមៈ បាទ! រៀនបានថ្នាក់ទី១២ ចាស់ហ្អី?

វណ្ណៈ ចឹងពូអត់ចេះអក្សរទេចឹង?

រីមៈ អត់ ចេះបានតិចៗ ។

វណ្ណៈ ចុះម៉េចបានពូឈប់រៀនកាលនោះ?

រីមៈ ចុះគេប្រាប់ថារៀនចប់ហើយគេបញ្ជូនទៅណេះទៅណោះ ខ្វះគេឲ្យធ្វើទាហានហើយខ្ញុំគេឲ្យត្បាញក្រមា ត្បាញបាវ ទៅរត់សំបុត្រគេហៅនិរសាហ្នឹងណាស ។

វណ្ណៈ ចុះ៧៣ ឬ៧៨ពូចូលធ្វើ?

រឹមៈ ៧៨ចូល ។

វណ្ណៈ និរសាស្រុកឬឃុំ?

រឹមៈ និរសាជុំវិញមន្ទីដូចថាក្រសួង សិប្បកម្មណាស!

វណ្ណៈ នៅឯណា? ស្រុកនៅឯណា?

រឹមៈ នៅឱរ៉ាល់ហ្នឹង ។

វណ្ណៈ មន្ទីរហ្នឹងលេខប៉ុន្មាន?

រឹមៈ អត់សូវដឹងទេតែគ្រាន់តែមន្ទីរសិប្បកម្មគេដាក់ចឹងណាស សិប្បកម្មត្បាញក្រមា ត្បាញបាវ ហើយធ្វើរទេះធ្វើអីហ្នឹងណាស!ខ្ញុំចាំបានតែប៉ុណ្ណឹង ។

វណ្ណៈ ចុះពូអត់មានធ្វើនិរសាជាមួយមេណាមួយទេ?

រឹមៈ អត់ទេ នៅមន្ទីរគ្រាន់តែពេលគេប្រញាប់អីជួយគេហើយមើលគោក្បែៗហ្នឹងដែរ ត្បាញបាវ ហុចនេះហុចនោះអី នៅស្ទើរដែរអាយុ១៨លេងគ្រាន់ដែរហ្នឹងមិនសូវគិតគូរអីប៉ុន្មានទេ ។

វណ្ណៈ បាទ!ហើយនឹកនាផ្ទះសំបែងអីទេ?

រឹមៈ នឹកចេះតែនឹកហើយតែមិនហ៊ានថាទេខ្លាចគេយកទៅវាយចោល ។

វណ្ណៈ បាទ!ចុះនៅតំបន់ហ្នឹងតំបន់ប៉ុន្មានដែរ?

រឹមៈ កាលនោះតំបន់៣២ ។

វណ្ណៈ ៣២ឬ៣៣?

រឹមៈ តំបន់៣២ ។

វណ្ណៈ ភូមិភាគ?

រឹមៈ ដូចជាភូមិភាគបច្ចឹម ទេបើក្មួយចាំអីដាក់ដង វាដូចជាយូរពេកហើយតាំងពីនោះមក ។

វណ្ណៈ ចុះប្រធានភូមិភាគពូស្គាល់ទេ?

រឹមៈ ប្រធានភូមិភាគអត់មានស្គាល់ទេ ។

វណ្ណៈ គណៈតំបន់អី?

រឹមៈ គណៈតំបន់ស្គាល់តែ តាប៉ាល់ មួយ ។ តំបន់កាលនោះដូចជាខេត្តឬយ៉ាងម៉េចហ្នុំខ្ញុំអត់ដឹងដែរ ។

វណ្ណៈ បាទ!តាប៉ាល់ហ្អី?

រឹមៈ បាទ!

វណ្ណៈ តាប៉ាល់ ហ្នឹងក្រោយមកគេចាប់គាត់ដែរឬយ៉ាងម៉េច?

រីមៈ អត់ចាប់ទេ ។

វណ្ណៈ គាត់នៅរហូត?

រីមៈ បាទអត់ទៅណាទេនៅរហូត ។

វណ្ណៈ ចឹងពូស្គាល់ តាសាន ទេ?

រីមៈ តាសាន នៅផ្ទះក្បែរនេះហ្នឹង?

វណ្ណៈ បាទ!

រីមៈ តាសាន គាត់នៅខាងកងទ័ពតែនៅតំបន់នេះមានជំនាញខុស ៗ គ្នាដូចយើងនៅតាមតំបន់នៅតាមខេត្តខុសគ្នាចឹងអត់សូវដឹងរឿងទេ ។ តាសាន គាត់ខាងកងទ័ពតែបើខាងអីទៀតខ្ញុំអត់ដឹងទេ ។

វណ្ណៈ តាសាន កាលមុនគាត់កាន់ខាងកំពង់ស្ពឺហ្នឹងគាត់ប្រធានតំបន់បន្ទាប់ពីចាប់ ជុរ ចេត ។

រីមៈ ខ្ញុំអត់ដឹងថាគេចាប់ឆ្នាំណាទេ បើតាប៉ាល់ខ្ញុំដឹងគាត់នៅហ្នឹងរហូត ។ ដល់ឆ្នាំ៧៥ ពេលគេរំដោះខ្ញុំមិនដឹងថាថ្ងៃណាទេតែពួកខ្ញុំគេមិនទុកចិត្តដោយសារនៅជាមួយ តាគ្រីប ហ្នឹងក៏គេដកគាត់ចេញដោយសារគាត់ធ្វើបាត់ក្របីមួយ ។ តាមពិតទៅដោយសារតែអត់ម្ហូបពេកហ្នឹងណាសក៏យកក្របីហ្នឹងទៅបាញ់ធ្វើម្ហូបតែក្របីប្រហែលមួយរយគីឡូយកមកហូបតែប្រហែលកន្លះគីឡូទេគ្នាប្រហែលហាហុកសិបនាក់ តែគេមិនទុកចិត្តគាត់ខ្លាចក្បត់ ចឹងគេដកគាត់ចេញទៅហើយខ្ញុំក៏ធ្លាក់មកធ្វើការនៅកងចល័ត ។ កងចល័តហ្នឹងកងចល័តវែកដីហើយវារួមផ្សំហ្នឹងចិត្តខ្ញុំសប្បាយដែរ នៅស្មារដែរអារបៀបនៅក្មេងពុំតែគេចាក់មេក្រូទ្រឹប ៗ ហ្នឹងហើយគេច្រៀងគេឲ្យខ្ញុំទៅហ្នឹងគេដែរ ។ មានការលំបាកដែរដូចថាខាងបង ៗ នារីដែលស្គាល់គ្នាហ្នឹងថាឲ្យខ្ញុំទៅវិញ ខ្ញុំថាអត់ទៅទេ តែមកហើយមកហើយកុំឲ្យពិបាកទៅវិញស្គាល់ ៗ គ្នាហ្នឹង ។ ដល់ពេលមានបុណ្យទានអីចឹងជួបគ្នាគេថាខ្ញុំអីក៏ស្គមម្លេះ? ពេលបុណ្យដូចយើងចូលឆ្នាំចឹងណាស ហើយដល់ពេលឃោសនាការគេចឹងគេឲ្យយើងឡើងធ្វើចំណាប់អារម្មណ៍ម្នាក់ម្តងអត់មាន លេងឈ្មូងលាក់កន្សែងអីទេ ។

វណ្ណៈ ហ្អស! ចឹងអត់ទាន់ចូល៧៥ ទេបើដល់៧៥ គេមិនឲ្យលេងទេ ។

រីមៈ ទេ! ចូលដល់៧៦ ហើយ ។

វណ្ណៈ ៧៦ មានលេងអីបានដែរ?

រីមៈ អត់ទេ អត់មានលេងលាក់កន្សែងអីទេតំរង់ជួររង់ចាំស្តាប់ផែនការគេតែម្តង ។

វណ្ណៈ ចេះទៅខ្ញុំសួរកុំឲ្យច្រឡំ ។ ចុះពេលដែលដែលខ្មែរក្រហមរំដោះបាននៅថ្ងៃទី១៧មេសាឆ្នាំ១៩៧៥ហ្នឹង ពូមានគេជម្លៀសទៅណាទេ?

រីមៈ ផ្លាស់ឲ្យទៅកងចល័ត ។

វណ្ណៈ៖ កងចល័តនៅឯណា?

រីមៈ កងចល័តនៅឃុំកន្ទួតហ្នឹង ។

វណ្ណៈ៖ កន្ទួតនៅខេត្តណាវិញ?

រីមៈ នៅកំពង់ស្ពឺហ្នឹង ។

វណ្ណៈ៖ ដកចេញពីនិរសារហើយចឹង?

រីមៈ ចេញពីមន្ទីរ ។

វណ្ណៈ៖ និរសាមន្ទីរមកកងចល័តនៅឯណា?

រីមៈ កងចល័តនៅកន្ទួត ។

វណ្ណៈ៖ កំពង់ស្ពឺដែរ?

រីមៈ បាទ!

វណ្ណៈ៖ ចឹងពូកាលនោះអត់មានកាន់កាំភ្លើងកាន់អីទេ?

រីមៈ កាន់ និរសាបានកាត់មួងៗមិនសូវយកចិត្តទុកដាក់អីទេ យូរៗកាន់មួងខ្ជិលនោះ ។

វណ្ណៈ៖ ពូខុសអីបានគេដកមកកងចល័ត?

រីមៈ គេអត់ទុកចិត្តមេនោះដកទាំងមេដកទាំងខ្ញុំ ។

វណ្ណៈ៖ មេណា?

រីមៈ មេហ្នឹងគាត់ប្រធានមន្ទីរសិប្បកម្មនោះ!

វណ្ណៈ៖ មេហ្នឹងឈ្មោះអី?

រីមៈ ឈ្មោះ គ្រីប ។

វណ្ណៈ៖ គេចាប់ខ្លួនគាត់ហ្អី?

រីមៈ អត់ចាប់ទេគ្រាន់តែដកចេញអត់ឲ្យទទួលការងារអីចឹង ។

វណ្ណៈ៖ ទៅធ្វើកងចល័តវិញហ្អី?

រីមៈ បាទ!

វណ្ណៈ៖ ពូទៅកងចល័តហ្នឹងគេឲ្យធ្វើអីខ្លះ?

រីមៈ គេឲ្យរែកដី រែកភ្លឺស្រែ ។

វណ្ណៈ៖ ពីណាប្រធាននៅហ្នឹង?

រីមៈ ប្រធានឈ្មោះ ដូ ។

វណ្ណៈ៖ នៅកងចល័តហ្នឹងមានគ្នាប្រហែលប៉ុន្មាននាក់?

រីមៈ	មានប្រហែល១០០នាក់ ១៥០អីក្មេចអស់ហើយតាំងពី៧៦ឯណោះ ។

វណ្ណៈ:	១៥០នាក់ពូហ្ន៎?

រីមៈ	បាទ]

វណ្ណៈ:	នៅកងចល័តហ្នឹងគេមានលត់ដំអីទេ? ហូបចុកអីយ៉ាងម៉េចដែរ?

រីមៈ	ហូបចុកហ្នឹងស៊ីសងហ្នឹងជីវភាពដែរ បើជីវភាពយើងធូរគេឲ្យហូបគ្រាន់ដែរបើអត់ធូរធារទេដូចខែពោតគេដកអង្ករមួយកំប៉ុង ។ ម្នាក់ហូបអង្ករមួយកំប៉ុងដល់គេឲ្យពោតពីរកំប៉ុងដាំលាយបាយតែបាយវាល់ វាល់មួយចានគ្រាន់ធំដែរតែមើអ្នកធើការច្រើនហូបអត់ឆ្អែតទេទាល់តែយើងហូបសម្លច្រើន តែសម្លគេថែមជាប់បើបាយសន្សំសំចៃបន្តិចមិនមែនចេះតែពើតបាយខ្លួនឯងដូចថាការផាររួមអាហ្នឹងយើងដឹងច្បាស់ហើយ ។ យើងត្រូវដឹងក្នុងចិត្តថាបាយកុំហូបដល់ដល់ព្រៀបពេកតែបើសម្លឺយកឲ្យពេញទៅអត់អីទៅយើងឆ្អែតធ្វើការបានយូរ ។

វណ្ណៈ:	បាទ!ចុះពូដូចថាធ្វើការនៅហ្នឹងមានគ្នាពូបាត់ខ្លួនដោយសារអង្គការចាប់ចឹងមានទេ?

រីមៈ	បាត់តើតែមិនដឹងគេយកទៅណាខ្ញុំអត់ដឹងទេ ។

វណ្ណៈ:	ពូឃើញគេចាប់ផ្ទាល់ភ្នែកទេ?

រីមៈ	អត់ទេឃើញតែបាត់ចឹងទៅគេថាកុហកយកទៅចាប់ជ្រូក ។ ខ្ញុំចេះមានគេស្រលាញ់រាប់អានគេអត់ឲ្យខ្ញុំទៅមិនទាន់ដល់អាយុក៏មិនដឹង ។ ខ្ញុំស្រលាញ់បង១ណាស់គេចាប់គាត់ទៅដាក់ឡានប្រាប់ថាទៅចាប់ជ្រូកហើយខ្ញុំថាចាំខ្ញុំផងចាំខ្ញុំទៅជួយចាប់ ។ ហើយចឹងទៅគេអត់ឲ្យទៅខ្ញុំចង់យំដែរគេរករឿង ដល់ពេលទៅក៏បាត់ទៅខ្ញុំផាកចេញមកមិនដឹងត្រូវទៅណាទេ ។

វណ្ណៈ:	ចុះពូកាលជំនាន់៧៦ ៧៧ហ្នឹងមានដឹងថាគេសម្លាប់មនុស្សទេនៅតាមភូមិ ឃុំអី?

រីមៈ	ដឹងតើ តែអ្នកណាសម្លាប់ខ្ញុំមិនដឹងទេគ្រាន់តែឃើញឆ្អឹងប៉ុណ្ណឹងទេ ។

វណ្ណៈ:	ចុះនៅកងចល័តពូកាន់តែមានអ្នកថ្មីចូលឬក៏មានដកអ្នកចាស់ចេញកាន់តែតិចទៅៗទេ?

រីមៈ	អត់សូវមានទេ មានតែ៩នាក់ហ្នឹងទេហើយវាក៏ចប់រឿងទៅ ។ អ្នកខ្លះចេះតែមានផ្លាស់ទៅកន្លែងនេះកន្លែងនោះខ្ញុំក៏បែកគេគេក៏បែកខ្ញុំ ។

វណ្ណៈ:	ចឹងពូនៅកងចល័តរហូតដល់បែក៧៩យួនចូលឬយ៉ាងម៉េច?

រីមៈ	អត់ទេ ខ្ញុំនៅវែកដីមួយរយៈ លើកភ្លឺ ភ្ជួរស្រែបានប្រហែលមួយឆ្នាំផ្លាស់ទៅលើកទំនប់ទៀតរួចហើយទៅនៅកងចល័តស្រុកវិញហើយ ។ នៅស្រុកគេលត់ដំខ្ញុំមួយរយៈកន្លះខែ ។

វណ្ណៈ:	ឆ្នាំណាពូទៅស្រុក?

រីមៈ	ឆ្នាំ៧៦ដែរតាមមើលបែបខែ១១ ។

វណ្ណៈ:	នៅស្រុកធ្វើអីដែរ?

រីមៈ គេឲ្យវែកដី លើកទំនប់ ។

វណ្ណៈ កងចល័តទៀត?

រីមៈ កងចល័តទៀត គេឲ្យលត់ដីមួយសារទៀត ។

វណ្ណៈ នៅហ្នឹងការហូបចុកលំបាកម៉េចដែរ?

រីមៈ អត់អីទេ ជីវភាពរបស់ពួកខ្ញុំ ស្រូវដែលធ្វើបានគេយកទៅស្រុកតាមការផ្គត់ផ្គង់របស់គេដែរ ។ ការហូបចុកហ្នឹងវាសមល្មមដែរ តែវាមិនបានគ្រប់ទេមិនដូចឥឡូវហ្នឹងទេ ។ អាខ្លះទៅវាសមល្មមខ្លះទៅហូបបបរសុទ្ធៗខ្ញុំដើរមើលដែរហ្នឹង

វណ្ណៈ ចុះពូនៅកំពង់ស្ពឺមានដឹងថាកន្លែងខ្លះមានគុកមានអីដឹងទេ?

រីមៈ អត់ទេ អត់ដឹងទេឮតែគេថាគុក៩៩អីណាឮតែគេថាទេ ។

វណ្ណៈ ចុះឆ្នាំ៧៧ ៧៨អីពូទៅណាទៀត?

រីមៈ ៧៦....

វណ្ណៈ ៧៦មកដល់ស្រុកហើយ?

រីមៈ មកដល់ស្រុក ដល់៧៧ គេឲ្យទៅធ្វើទាហានចុះជំនាន់នោះគេរើសកងទ័ពវិញហើយ ខ្ញុំអរគ្រាន់បើដែរ ។

វណ្ណៈ ចឹងចូលយោធាវិញ គេទុកចិត្តវិញហើយ?

រីមៈ បាទ!

វណ្ណៈ យោធាទៅច្បាំងនៅព្រំដែនឬយ៉ាងម៉េច?

រីមៈ អត់ទេ អត់បានច្បាំងទេ ។ យោធាទៅនៅពោធិ៍បឹងបានមួយឆ្នាំ ។

វណ្ណៈ នៅឯណា?

រីមៈ នៅតាមពោធិ៍បឹងមិនដឹងនៅស្រុកអីទេ ។

វណ្ណៈ ឃុំសំឡូតពោធិ៍បឹង?

រីមៈ គំលត គំលតពោធិ៍បឹងមិនដឹងនៅឯណាទេដូចនៅស្រែអំបិលកោះកុងវិញ ។

វណ្ណៈ គំលត ពោធិ៍បឹង?

រីមៈ បាទ!

វណ្ណៈ ស្រុកអីគេ?

រីមៈ កាលនោះនៅក្នុងខេត្តកំពង់ស្ពឺ កាលនោះឱរ៉ាល់ដដែល តែក្រោយមកថាស្រុកថ្ពោង ។

វណ្ណៈ ស្រុកថ្ពោង?

រីមៈ បាទ!

វណ្ណៈ	ចុះនៅនោះធ្វើយោធាយ៉ាងម៉េច?

រឹមៈ	យោធាធ្វើស្រែធ្វើអីធម្មតាចឹង ។

វណ្ណៈ	យោធាធ្វើស្រែទៀត?

រឹមៈ	បាទ!រៀនបច្ចេកទេសបានខ្លះ ។ ធ្វើស្រែណាស ខ្ទាំងណាស់កសាងប្រទេស ។

វណ្ណៈ	ពីណាដឹកនាំកាលហ្នឹង?

រឹមៈ	កាលនោះវីរៈសេនាធំឈ្មោះ តាអួន ។

វណ្ណៈ	ចុះពូមានគ្នាច្រើននាក់ទេនៅកន្លែងហ្នឹង?

រឹមៈ	ច្រើន!

វណ្ណៈ	ប្រហែលប៉ុន្មានរយទៅ?

រឹមៈ	មិនដឹងប៉ុន្មានរយទេ តែដឹងតែថានៅខាងខ្ញុំខាងពោធិ៍បឹងមួយវីរៈសេនាតូចមានមួយកងរយសែ ហាសិបនាក់ណ៎?

វណ្ណៈ	បាទ!

រឹមៈ	មួយកងរយវាអាចបីវីរៈសេណាតូច ។

វណ្ណៈ	បាទ!ចឹងមនុស្សនៅហ្នឹងរាប់រយនាក់ដែរ?

រឹមៈ	អត់ដល់ទេប្រហែលហាសិបនាក់អីប៉ុណ្ណឹងទេអត់ដល់រយទេប្តូកខ្ញុំភ្លេចទេមិនដឹង ។

វណ្ណៈ	នៅនោះធ្វើកងទ័ពនេ?

រឹមៈ	បាទ!

វណ្ណៈ	កងទ័ពហើយធ្វើស្រែ ។ ធ្វើស្រែដល់ឆ្នាំណា?

រឹមៈ	ធ្វើស្រែរហូតដល់៧៧ ៧៨ ដល់៧៨បានគេដក គេដកទៅនៅកោះកុងស្រែអំបិលនេះគេដកទៀតហើយ

វណ្ណៈ	កោះកុង?

រឹមៈ	បាទ! នៅស្រែអំបិលនេះ ។

វណ្ណៈ	មកដល់កោះកុង ស្រែអំបិលធ្វើអីវិញ៧៨ហ្នឹង?

រឹមៈ	អាហ្នឹងឡើងដល់ភូមិភាគអីក៏មិញ្ជីហ្នឹទេ!អត់មានធ្វើអីទេ ។ ធម្មតាហាត់អីតិចតួចធ្វើការដូចប្រជាជន ការពារប្រទេស ។

វណ្ណៈ	ការពារយ៉ាងម៉េចទៅ?

រឹមៈ	ការពារកុំឲ្យខ្មាំងមកអុកឡុកចឹងទៅណាស! មើលស៊ើបមានគេញមានអីមកខ្លាចថែខ្មរសណាស ។

វណ្ណៈ ពីណាធ្វើប្រធាននៅស្រែអំបិលហ្នឹង?

រីមៈ កាលហ្នឹងអ្នកណាទេភ្លេចបាត់ហើយ តាហយ គាត់ខាងវិរៈសេនាតូច ។

វណ្ណៈ ហយហ្អី?

រីមៈ បាទ!

វណ្ណៈ នៅទីនោះហូបចុកគ្រប់គ្រាន់ទេ?

រីមៈ មិនអីទេគេឲ្យគ្រប់គ្រាន់ដប់ថ្ងៃអីគេឲ្យបន្ថែម ហើយប្រជាជននៅជិតនោះគាត់ចិត្តល្អឲ្យបន្ថែម ហូបខាងកុមារក៏ឲ្យមកដែរ ហើយកន្លែងយាយៗក៏ឲ្យមកដូចកន្លែងធ្វើបុណ្យចឹងណាស គាត់ស្រលាញ់កងទ័ព ។

វណ្ណៈ ចឹងនៅកោះកុងការពារកុំឲ្យថៃចូលមកប្អូយ៉ាងម៉េច?

រីមៈ អត់ដឹងទេគេគ្រាន់តែឲ្យនៅឈរជើងការពារធម្មតាចឹងណាស!

វណ្ណៈ ពូដើរពេលយប់អីមានដើរទេ?

រីមៈ ដើរតើទាក់ទងគ្នា ។

វណ្ណៈ ចុះពូដែលឃើញគេចាប់ប្រជាជនចាប់អីនៅជិតៗនោះទេ?

រីមៈ អត់ទេឮតែគាត់ថាមាន ថាកូនៗមកពីខាងណាអីក៏ស្លូតបូតម្លេះហើយចុះកូនៗមុនម៉េចក៏យ៉ាប់ម្លេះឲ្យតែខ្ញុំធ្វើអីអត់កើតហ្នឹងយកពួកខ្ញុំទៅមើលតាមភ្លឺស្រែ ហើយចុះកូនៗមកពីណាក៏ល្អៗម្លេះ ។ អង្គអីបើកឲ្យគាត់គ្រប់ចឹងគាត់ឆ្ងល់ដូចថាគ្នាប៉ុន្មាននាក់បើកឲ្យគាត់មួយថ្ងៃពីរកំប៉ុងហើយដប់ថ្ងៃបើកឲ្យគាត់ម្តងខ្លាចគេត្រួតពិនិត្យខ្លាចគេថាពួកក្បត់ពួកអីចឹងព្រោះអ្នកមុនៗធ្វើបាបគាត់ ។ គាត់ឆ្ងល់ដែរមិនសូវហ៊ាននិយាយទេខ្លាច ។

វណ្ណៈ ចឹងគាត់ថាពួ កមុនពិបាក?

រីមៈ បាទ!ពិបាកហូបបាយមិនឆ្អែត បបរមិនដឹងកូនៗមកពីណាល្អបានហូបគ្រប់ កងមេម៉ាយៗគាត់និយាយ ខាងម៉ាស៊ីនកិនស្រូវក៏គាត់និយាយ ។ ខ្ញុំទៅម៉ាស៊ីនកិនស្រូវបើកឲ្យពួកគាត់ខាងកងចល័តជង ប្រជាជនជង ។

វណ្ណៈ ចុះពូនៅហ្នឹងដែលឃើញគណៈប្រតិភូធំៗគេទៅកន្លែងពូដែរអត់?

រីមៈ អត់មានទេ ។

វណ្ណៈ ចុះពូដែលទៅលេងភ្នំពេញដែរទេ?

រីមៈ អត់ទេ ។

វណ្ណៈ អត់ដែលមកទេ?

រីមៈ បាទ!

វណ្ណៈ៖ ចុះគេមានឲ្យវ៉ាន់តួនាទីពូអីគេ?

រីមៈ អត់មានទេគ្រាន់តែកូនទាហានធម្មតា ។

វណ្ណៈ៖ ៧៨ដល់៧៩ហ្នឹងពូនៅស្រែអំបិល?

រីមៈ បាទ!

វណ្ណៈ៖ ចុះពេលវៀតណាមចូល៧៩ហ្នឹងពូរត់ទៅណា?

រីមៈ ខ្ញុំទៅខាងកំពង់ចាមវិញ ។

វណ្ណៈ៖ ហ្អាក! ទៅកំពង់ចាម?

រីមៈ បាទ!បញ្ជ្រាសចឹងវិញ ។

វណ្ណៈ៖ រត់ទៅតាមពីណាទៅកំពង់ចាម?

រីមៈ អត់តាមពីណាទេទាហានរត់ទៅទប់ យួនចេះតែមកខ្ញុំចេះតែទៅមិនខ្វាចគ្នាទេណាស!

វណ្ណៈ៖ ហ្អាក!៧៩ហ្នឹង? ៧៨ទេហ្អីដែលទៅទប់? ៧៩យួនចូលដល់ភ្នំពេញហើយ?

រីមៈ អឺហ្នឹង!ចូលដល់ព្រឹក ។ យួនចូលដល់ខ្ញុំចេញទៅតាមព្រែកក្ដាម ដល់ទេយួនសួរថា ទៅណា? ខ្ញុំថាទៅវ៉ៃយួននៅបូព៌ា ដល់ហើយគាត់ថាកុំទៅបូព៌ាណាស ទៅកំពង់ចាម!

វណ្ណៈ៖ ហ្អឺស!យួនសួរម៉េច?

រីមៈ សួរតែម៉ង!

វណ្ណៈ៖ ចុះបើជួបយួនហើយសួរយួនម៉េច?

រីមៈ សួរ!អត់វ៉ៃគ្នាទេ រថក្រោះគេក៏ទៅឡានខ្ញុំក៏ទៅហើយគេប្រាប់ថា កុំចុះពីលើឡានហើយឡានធំៗ បើកឲ្យកិតៗគ្នាប្រយ័ត្នគេដាក់មីនកុំឲ្យខាតកងទ័ពច្រើនព្រោះមេគេទៅមុនណាស!

វណ្ណៈ៖ ហ៊ឺ...ពូច្រឡំហើយ!

រីមៈ ថាអត់ច្រឡំទេ ៧៨ហ្នឹងនៅអ៊ុល!ហើយណាស ដល់៧៩យួនចូលដល់ភ្នំពេញមិនដល់មួយអាទិត្យទេណាសចូលដល់បទចម្រៀង "ឱភ្នំពេញអើយ " ។

វណ្ណៈ៖ ពេល៧៩ហ្នឹងយួនចូលដល់ភ្នំពេញហើយ!

រីមៈ ចូលឲ្យត្រឹមតែម្ដង ។

វណ្ណៈ៖ អ្នកនៅភ្នំពេញទាំងទាហានទាំងប្រជាជនគឺរត់ប្រាសចេញទៅអស់ហើយ ។

រីមៈ ហ្នឹងហើយ!គេរត់តែខ្ញុំចេញទៅបញ្ច្រាសចឹងទៅ ទៅទប់នៅស្គន់ ត្រាងនៅទីនោះ ។ អាគេចេះតែមក ខ្ញុំចេះតែទៅ បានទៅត្រពាំងព្រីង កំពង់ធំបានទៅកំពង់ឆ្នាំងកាត់មកដល់បណ្ដាយ ។ ជំនាន់នោះវាភ្លេចចាំខ្លះ មកតាមផ្លូវ៥៦ចឹងរហូតមកទេដល់សព្វថ្ងៃនេះតាមអាស៊ីងមេទឹកគេហៅថ្មដានោះណាស!

វណ្ណៈ៖ ចុះពេលចប់ ចុងក្រោយពូរត់ទៅណា?

រឹមៈ រត់មកលិចដែរ!

វណ្ណៈ៖ ដាយដែន?

រឹមៈ បាទ!មកហ្នឹងដែរ ។

វណ្ណៈ៖ ចឹងចោលរថក្រោះចោលអីដែរ?

រឹមៈ ចោល!ចប់បែកពោធិ៍សាត់ចប់អស់ហើយមកដល់នេះប្រហែលឆ្នាំ៨០ ៨១ហើយវ៉ៃរហូត ។

វណ្ណៈ៖ ឆ្នាំ៨០វ៉ៃនៅឯណា?

រឹមៈ វ៉ៃនៅអាយើងចិនយំអីហ្នឹងតាម៥៦ហ្នឹង តែមិនវ៉ៃខ្លាំងទេដើររកក្តួច បាញ់សត្វខ្ទួនឯងហ្នឹង គ្រាន់តែព្រួយឈ្លួនមករត់ទៅទៀតហើយ ។

វណ្ណៈ៖ ពូបើតាមគិតទៅ ទៅដល់ដាយដែនដំបូងពូនៅម្តុំណា?

រឹមៈ នៅម្តុំដួរព្រំដែនហ្នឹងតែម្តងនៅផ្ទះពីរហ្នឹង ។

វណ្ណៈ៖ ទៅខាងម៉ាឡៃ ឬសំឡូតកាលនោះ?

រឹមៈ អត់ទេនៅខាងវាលវែងថ្មដាហ្នឹងម៉ង ។

វណ្ណៈ៖ ចឹងឆ្នាំ៨០នៅថ្មដា?

រឹមៈ បាទ!

វណ្ណៈ៖ ថ្មដាហ្នឹងទៅវ៉ៃជាមួយយួន?

រឹមៈ បាទ!

វណ្ណៈ៖ ចុះអ្នកណាប្រធានកងពលនៅទីនោះ?

រឹមៈ កងពល...តា ដាន អៀង ដាន កាលហ្នឹង ។

វណ្ណៈ៖ អៀង ដាន ហ្អី?

រឹមៈ បាទ!

វណ្ណៈ៖ ប្រធានកងពលលេខប៉ុន្មាន?

រឹមៈ កងពលទី២កាលហ្នឹងមិនទាន់រំលាយចូលទី៥ទេ ។

វណ្ណៈ៖ ចុះតា វ៉ែននោះមិននៅកងពលទីពីរដែរ?

រឹមៈ តា វ៉ែន...កងពលមានកងពលតូច កងពលធំ គាត់កងពលធំហើយ អ៊ឹ វ៉ែន ។

វណ្ណៈ៖ នេះកងពលតូចណ៎?

រឹមៈ បាទ!កងពលតូច ដឹងតែប្រធានៗអនុប្រធានខ្ញុំមិនដឹងទេ ។ ខ្ញុំរត់មកជាមួយ តាដានមុនមក ។

វណ្ណៈ៖ តា វ៉ែន ហ្នឹងកូនប្រសារ តា ម៉ុក ហ្អី?

រីមៈ បាទ!ពុកគេថាកូនប្រសារ តា ម៉ុក ។

វណ្ណៈ កាចទេ?

រីមៈ កាច!

វណ្ណៈ កាចដែរ?

រីមៈ បាទ!

វណ្ណៈ ពូ!ខ្ញុំសុំបន្តទៅទៀតដូចថាពេលវើជាមួយវៀតណាមហ្នឹងខាងខ្មែរក្រហមនិងខាងវៀតណាម មានស្លាប់ដូចគ្នាជារឿងធម្មតាទេណ៎?

រីមៈ បាទ!ធម្មតាទេ ។

វណ្ណៈ ចុះវើហ្នឹងមានប្រាក់ខែដែរអត់?

រីមៈ អត់ទេ ។

វណ្ណៈ គ្មានប្រាក់ខែទេ? ដែលឃើញ សុន សេន អីគាត់មកហ្នឹងទេ?

រីមៈ ដែលឃើញម្តង ។

វណ្ណៈ តា ខៀវ សំផន អីមានដែលមកព្រំដែនខាងនេះទេ?

រីមៈ មកកាលនេះរៀបចប់ដែរហើយទេ ។

វណ្ណៈ ចុះ តា ម៉ុក?

រីមៈ គាត់ក៏ជួបដែរ ។

វណ្ណៈ កាចទេ តា ម៉ុក?

រីមៈ តា ម៉ុក ជាមួយខ្ញុំមិនអីដែរទេខ្ញុំធ្លាប់ចូលលេងផ្ទះគាត់អត់មានអីឲ្យគាត់ផង ទុកគាត់ដូចជាព្រះ ដូចជាម៉ែជាឪចឹងណាស គាត់ស្លូវដែរហើយ ។

វណ្ណៈ កាលនោះពូឡើងវើខ្លាចទេ?

រីមៈ មុនដំបូងខ្លាចដល់យូរទៅលែងអីហើយ ។

វណ្ណៈ យូរទៅលែងអីហើយណ៎?

រីមៈ បាទ!យូរៗធម្មតា ខ្លាចត្រង់អត់ផង ស្លាប់ផង ។ ផាប់មួយថ្ងៃពីរបី ជួនទៅអត់ទទេ ។

វណ្ណៈ ចុះពូដើរទៅខ្លាចជាន់មីនជាន់អីទេ?

រីមៈ ខ្លាចដែរហ្នឹងប៉ុន្តែមិនដឹងធ្វើម៉េច ។

វណ្ណៈ មកប្រាំវៗវើព្រឹបម៉ង?

រីមៈ បាទ!

វណ្ណៈ ចុះបើមេបញ្ជាការឲ្យលួនទៅជិតបន្ទាយយួនបន្ទាយអីហ៊ានទេ?

រីមៈ លូន!លូនទៅជួនណាមួយថ្ងៃហ្នឹងមួយថ្ងៃវាស់ល្ងាចបានប្រហែលចម្ងាយឡានហ្នឹងប្រហែល២៥ ម៉ែត្រទាំងរាវមីនទាំងអីណាស ហើយត្រលប់មកផ្ទះវិញចាំស្អែកឡើងចាំទៅទៀត ។ រយៈតែពីរម៉ែត្រហ្នឹងអស់លទ្ធភាពហើយតែឃើញសំណាមយើងមកគេឃ្មាងណាស ចឹងយើងទាល់តែបញ្ញាតែតាមដានយូរអត់បានទេ ។

វណ្ណៈ ចឹងកាលធ្វើសង្គ្រាមយ៉ាប់ណាស់ពូហ្ន៎?

រីមៈ យ៉ាប់ណាស់ ការពារតែជីវិតទេបើដល់ពេលល្ងាចដឹងតែរស់ហើយ ។

វណ្ណៈ ចុះពូអត់ដែលចេញទៅសំឡូតទៅអីនៅហ្នឹងរហូតដល់សមាហរណកម្មហើយ?

រីមៈ ផ្លាស់ដែរដូចថាទៅជួយគេមួយក្លែតៗដល់សំឡូតអី តែខ្ញុំមិនជាអ្នកវៃអ្នកអីអាកាលផ្លាស់ទៅគេឲ្យខ្ញុំកាន់ឃ្លាំងកអង្ក ឃ្លាំងគ្រាប់វិញរយៈពេលប្រហែលមួយឆ្នាំអាហ្នឹង៨៥ ហើយគេឲ្យខ្ញុំទៅចាំ ។

វណ្ណៈ ចឹងកាលនោះដូចថាពូនៅប្រចាំការតែនៅទីនេះទេអត់មានទៅខាងម៉ាឡៃខាងអីទេ?

រីមៈ អត់ទេ ។

វណ្ណៈ ចឹងពេលពូបានប្រពន្ធរៀបការអីនៅឆ្នាំណាដែរ?

រីមៈ ខ្ញុំជំនាន់ អ៊ុនតាក់ ៩៣ហើយណ៎?

វណ្ណៈ : អ៊ុនតាក់?

រីមៈ ៩៣ ។

វណ្ណៈ កាល៩៣ អ៊ុនតាក់មកដល់នេះដែរ?

រីម : កាលនោះសំឡូតនៅឡើយ ការនៅសំឡូត ការហើយបានមកនៅទីនេះអត់ទាន់មានមនុស្សនៅផង ។

វណ្ណៈ កាលនៅសំឡូតបានប៉ុន្មានឆ្នាំដែរ?

រីម : ប៉ុន្មានទេភ្លេចហើយ ។

វណ្ណៈ ចុះកាលឆ្នាំ៨០ពូនៅវៃ?

រីម : បាទ!វៃហើយនៅក្រឡឹងៗណាស!

វណ្ណៈ ទៅសំឡូត ទៅសំឡូតហើយពូការនៅសំឡូត?

រីម : បាទ!រួចហើយបានមកចេះវិញ ។

វណ្ណៈ កាលការនៅសំឡូតហ្នឹងចាប់គូឬក៏មានភ្លេងមានអី?

រីម : មានភ្លេងអីដែរព្រោះយើងដល់ឆ្នាំ៩៣ហើយណាស!

វណ្ណៈ ៩៣ហ្នឹងនៅសំឡូតអ៊ុនតាក់ចូលអត់ដល់អត់បានបោះឆ្នោតទេហ្អី?

រឹម  :  ទេ!មិនដឹងទេដូចជាស្រពិចស្រពិលតែអ៊ុនគាត់មាន មានអ៊ុនគាត់មកចឹង ។

វណ្ណៈ:  បាទ!ពូធ្វើទាហានដល់សមាហរណកម្មចឹងហ្អី?

រឹម  :  បាទ!

វណ្ណៈ:  ចុះពូរាល់ថ្ងៃមានបើលុយបានទេ?

រឹម  :  អត់ទេខ្ញុំផ្ដាច់ខ្លួនមុន ខ្ញុំខ្ជិលទៅគ្រាន់តែសមាហរណកម្មហើយចប់ដែរទៅ!

វណ្ណៈ:  ហ៊ុ...មិនទុកឈ្មោះទុកអីបញ្ជូនទៅរដ្ឋាភិបាល រដ្ឋាភិបាលគេផ្ដត់ផ្ដង់ឲ្យរាល់ខែទេតើ?

រឹម  :  អត់!កាលនោះគេនាំគ្នាមកផ្ទះក៏មកដែរទៅ កាលនោះអ្នកគាមក៏ហួសអស់មិនតិចដែរ ។ម្យ៉ាង នឹកឃើញថារវល់តែចិញ្ចឹមខ្លួនឯងមិនបានទៅកាប់ចំការឲ្យប្រពន្ធកូនស៊ីទេយ៉ាប់ដដែល ចឹងគិត ទៅគិតមកធ្វើទាហានស្រួលមិនស្រួលប្រពន្ធអត់បាយយើងមានម៉ែឪឯណា ហើយកូននៅ តូចៗមានតែពីរនាក់ប្ដីប្រពន្ធចឹងខ្ញុំខ្ជិល ។ មិនមែនមានតែខ្ញុំទេ មេៗក៏គេឈប់ដែរ ។

វណ្ណៈ:  ចឹងពេលឈប់ទៅដាច់ឈ្មោះដែរ?

រឹម  :  បាទ!ឈប់ទៅគេស៊ីឈ្មោះហ្នឹង ។

វណ្ណៈ:  បាទ! ចឹងពេល៩៣ ពូការហើយមកនៅនេហវិញ?

រឹម  :  បាទ!

វណ្ណៈ:  ៩៣ ឬ៩៤មកដល់នេះ?

រឹម  :  បាទ! ៩៣ ៩៤ ទេដូចជា៩៥ហើយមកដល់នេះ ។

វណ្ណៈ:  ៩៥!ពេលពូមកដល់នៅកន្លែងតែម្ដងឬនៅកន្លែងណាផ្សេង?

រឹម  :  មិនមែននៅហ្នឹងទេ ភូមិដីក្រហមដូចគ្នាតែនៅខាងចុងឯលិច ដីក្រហមចុងខាងលិចហ្នឹងហៅថា ភូមិ៨០ចាស់ ។

វណ្ណៈ:  ចុះពូទៅនៅសំឡូតពីឆ្នាំណាដល់ឆ្នាំណា?

រឹម  :  នៅសំឡូត...

វណ្ណៈ:  បានប៉ុន្មានឆ្នាំដែរ?

រឹម  :  មើល ៨៥ ៨៦ ៨៧ សមាហរណកម្មឆ្នាំប៉ុន្មានអញ្ចេះ ពីពាន់...

វណ្ណៈ:  ៩៧ ៩៨ ។

រឹម  :  ៨៥ ខ្ញុំនៅដីថៃ នៅបានបីឆ្នាំ ។

វណ្ណៈ:  នៅសំឡូតបានបីឆ្នាំ?

រឹម  :  បាទ!

វណ្ណៈ:  នៅសំឡូតហ្នឹងគេឲ្យធ្វើទាហាន?

រឹម ៖ នៅសំឡូតគេឲ្យកាន់ឃ្មាំងអង្ករ ឃ្លាំងគ្រាប់ សម្ភារៈអីហ្នឹងណាស ចូលខាងឃ្លាំវិញម្តងហើយ ឃ្លាំងកងពល ។

វណ្ណៈ៖ បាទ!ចុះកាលនោះពូស្គាល់ តាដន អីទេ តាដន ខាងភស្តុភា?

រឹម ៖ ភ្លេចអស់ហើយតាមមើល...

វណ្ណៈ៖ តាមុត តាអីនោះ?

រឹម ៖ តាមុត? តាមុតនៅសព្វថ្ងៃនេះហ្នឹង?

វណ្ណៈ៖ បាទ!

រឹម ៖ តាមុត ងាក មុត?

វណ្ណៈ៖ បាទ!

រឹម ៖ ហួស...គេធំខ្ពស់ណាស់បើខ្ញុំកងទ័ពប្រជាជនធម្មតាហ្នឹងនិយាយមិនចេញទេ ។ វណ្ណៈ

វណ្ណៈ៖ អឺ មុតធំខ្ពស់ណាស់?

រឹម ៖ បាទ!គ្រាន់តែដើរទៅជិតហ្នឹងចង់យ៉ាប់ផងនិយាយឲ្យត្រង់ទៅបើប៉ុណ្ណោះហើយ ។

វណ្ណៈ៖ ចុះពូមកនៅទីនេះកាប់រានឆ្ការ ចុះប្រជាជនផ្សេងទៀតមកហ្នឹងកាប់រានព្រៃអីមានគ្រោះថ្នាក់ដោយសារមីនអីដែរ?

រឹម ៖ ដូចគ្មានទេប្រយ័ត្នៗទៅឃើមមានគ្រោះថ្នាក់ម្នាក់ឈ្មោះលោក ផុន តាមមើលគាត់យកគ្រាប់មកដាក់អញ្ចេះ ហើយគាត់ខែមិនដឹងគាត់ទុករបៀបយ៉ាងម៉េចហើយក៏ផ្ទុះទៅក៏ស្លាប់ទៅ ។

វណ្ណៈ៖ បាទ!

រឹម ៖ អាហ្នឹងនៅពេទ្យស្រុកណាស ហើយបើមានអ្នកផ្សេងទៀតក្រែងគេទៅរកខ្មឹមរកអីនៅខាងពីរបីគីឡូទៀតខ្ញុំមិនដឹងទេណាស!

វណ្ណៈ៖ បាទ!

រឹម ៖ ក្នុងភូមិហ្នឹងក្តាប់គ្នាឯងចឹងអត់មានប៉ះពាល់អីទេ ប៉ះពាល់តែម្នាក់ហ្នឹងទេ ។

វណ្ណៈ៖ ចុះកាលមកនៅទីនេះដំបូងគេថាមានព្រៃមានដីរមានខ្លាមែនហ្អី?

រឹម ៖ មាន មានខ្លាត្រីមានច្រើនតែនៅឆ្ងាយងអត់ជិតយើងទេប្រហែលមួយគីឡូពីភូមិ ស៊ីងណាស ។ កាលនៅភូមិ៨០ខ្ញុំទៅរកម្ជូបត្រីអីហ្នឹងជួបវាជួបខ្ទីងអីហ្នឹងណាស ។

វណ្ណៈ៖ ខ្ទីងធំដែរតើប៉ុនគោហ្នឹងទេ?

រឹម ៖ បាទ!ប៉ុណ្ណឹងហើយ!ធំជាងនេះក៏មានដែរ ។

វណ្ណៈ៖ ធំជាងគោទៀត?

រឹម ៖ បាទ!កបឿៗមិនដឹងកាលណាទឹមទេ ខ្ញុំបាញ់បានមួយ...

វណ្ណៈ បាញ់បានដែរ?

រឹម : បាទ!អាមេគេថាបាញ់តែមួយបានហើយអត់មានអីស៊ីមេគេថាចឹង រួចហើយបាញ់មិនដឹងអាតូចអាធំទេដល់តែពេលបាញ់ទៅមានអីណាបានអាធំ ដល់ទៅមេគេថាយកឲ្យអស់កុំឲ្យសល់យើងមើលតាមកំលាំងយើងផង កុំបាញ់អាធំពេក ខាតគ្មានខាតអ្នកណាខាតតែជាតិយើងដដែលទេរបស់យើងមេនិយាយណែនាំចឹង ។

វណ្ណៈ តែដោយសារយើងអត់អីហូបចេះតែបាញ់ទៅណ៎?

រឹម : បាទ!

វណ្ណៈ ហើយអាការអីបាញ់បានដែរ?

រឹម : បាន!

វណ្ណៈ ដាក់ដួលដែរ?

រឹម : បាន!ខ្ញុំមិនដែលបាញ់ដែរដល់តែដាក់ទៅថាតែតូចម៉ែអើយកឡើងប៉ុណ្ណឹង!

វណ្ណៈ ពូអ្នកបាញ់ផ្ទាល់?

រឹម : បាទ!ខ្ញុំគេឲ្យដាំបាយហើយទៅដងទឹកឃើញទឹកវិលៗតាមសាកមើលប្រហែលជាកន្ទុះម៉ោងមានអីណាធំក្លិនខ្ទីងឃើញបែរមុខមកវិញ ។ អាហ្នឹងដេកបែរមុខមកក្រោយវិញតើ វាយាមមើលទៅ គ្រាន់តែខ្ញុំអែបវាងើបបាត់ហើយ គ្រាត់តែងើបប្រែតហ្នឹងហើយត្រូវតែមួយកៃ វារត់មិនដឹងទៅដល់ណាប្រហែល៥០ម៉ែត្រ ។

វណ្ណៈ រត់បានទៀតហ្អី?

រឹម : បាទ!រត់បានដើងពីរ ហើយអាអ្នកថែមតាមក្រោយទៀតចំកឃើញតែក្បាលគ្រាប់អត់ធ្លាយដល់សាច់ផង តែបាញ់បានតែមួយហ្នឹង ។ បើគេវិញបាញ់ហើយចោលគេអត់ទៅយកឆ្ងាយពេក ។ ខ្ញុំថាខាតទេហ្អីកុំឲ្យមេដឹងតែមេដឹង មេរករឿងព្រោះយកអត់អស់ ។ ខ្ញុំស្តាប់តាមការណែនាំរបស់គាត់ បើបាញ់យកឲ្យអស់ ។

វណ្ណៈ ចុះឥឡូវសត្វចង់អស់ហើយហ្អីពូ?

រឹម : ចង់អស់ហើយ ។

វណ្ណៈ ហើយព្រៃឈើអី?

រឹម : វាចង់អស់ខ្លះហើយ ។

វណ្ណៈ ចុះប្រជាជនយើងប្រកបមុខរបរអី?

រឹម : សព្វថ្ងៃហ្នឹងដាំតែសណ្តែកហើយល្ងនៅដើមដៃហ្នឹង ហើយស្រូវ ។ ខ្លះដាំស្រូវ ខ្លះដាំសណ្តែកពោតមានតិចៗ ។

វណ្ណៈ  តាំងពីសមាហរណកម្មមកពូដែលទៅលេងស្រុកកំណើតទេ?

រឹម :  ដែលតើ ។

វណ្ណៈ  បានប៉ុន្មានដង?

រឹម :  ទៅបានពីរដង ។

វណ្ណៈ  ចឹង!ឥឡូវអត់ដែរលបានទៅទៀតទេ?

រឹម :  អត់ ។

វណ្ណៈ  ពេលទៅត្រូវចំណាយលុយច្រើនហ្អី?

រឹម :  មុនដំបូងអស់ម្ភៃម៉ឺន មិនអស់ផងតែដល់ទៅលើកទីពីរមិនដឹងអស់ប៉ុន្មានទេប្រពន្ធខ្ញុំ ។

វណ្ណៈ  ប្រពន្ធពូនៅស្រុកណាដែរ?

រឹម :  នៅមេង!

វណ្ណៈ  នៅមោងនេះទេ?

រឹម :  បាទ!

វណ្ណៈ  ហើយចឹងទៅពូអត់មានបំណងទៅរស់នៅស្រុកកំណើតវិញទេហ្អី?

រឹម :  ចេះតែចង់ទៅហើយតែវាអស់គេរកអីអស់ហើយ ទៅមានន័យអីក្រែងតែយ៉ាប់ដល់កូនក្រោយ បើគេនៅនោះយ៉ាប់ដែរបើយើងទៅវារឹតតែកុនទៀតហើយ ចេះតែគិតចឹងទៅ ។ ស្រុកកំណើតចេះតែចង់ទៅហើយ អូ...ចង់ណាស់ម៉េចៗឲ្យកូនវាស្គាល់ពូវា អឹវា បងជីដូនមួយវា ហើយចេះតែបារម្ភថាអត់ពីឯងទៅកូនមិនដឹងជាវាយ៉ាងណា តែទៅវាមិនរួចបែបនៅតែប៉ុណ្ណឹង ឯងមើលទៅ ។

វណ្ណៈ  ពូនៅនេះបានដីច្រើនទេ?

រឹម :  ហ៊ឹស ប្រហែល៥ហិចតាដែរ!

វណ្ណៈ  ៥ហិចតាអាហ្នឹងដីដែលធ្វើបានហ្នឹងដូចយើងចង់ដាំសណ្តែកដាំអីបានមិនមែនដី

រឹម :  អត់ទេនៅព្រៃ!របស់ខ្ញុំនៅព្រៃខ្លះមិនមែនធ្វើបានទាំងអស់ទេ ។

វណ្ណៈ  អាធ្វើដាំបានប្រហែលប៉ុណ្ណាដែរ?

រឹម :  បីហិចតា!

វណ្ណៈ  ចុះមេភូមិគាត់បានច្រើន គាត់បានដីល្អ ។

រឹម :  ហ្នឹងមេឃុំ!

វណ្ណៈ  ហ្អស មេឃុំ ចឹងពូទៅក្រោយចឹងទៅ?

រឹម :  បាទ!តហ្នឹងគេគិតៗចឹងទៅ ។

វណ្ណៈ៖ ចុះពូមកដល់សព្វថ្ងៃពូមានដែលស្តាប់រឿងតុលាការកាត់ទោសកាត់អីដែរទេ?

រឹម ៖ អត់ដែលផង! ខ្ញុំមិនដែលមានរ៉ាត់យូ៉អីហ្នឹងគេផង ។

វណ្ណៈ៖ ចុះពូមានដឹងថាមានអ្នកណាខ្លះនៅជាប់ឃុំនៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?

រឹម ៖ ពូតែគេនិយាយតៗគ្នាហ្នឹងភ្លេចបាត់ដឹងអ្នកណាថា ឌុច អីយ៉ាងម៉េចទេ ។

វណ្ណៈ៖ ចុះតានួន ជា ពូទេ?

រឹម ៖ អត់ទេ ព្រោះខ្ញុំមិនសូវយកចិត្តទុកដាក់ស្តាប់ផង ។

វណ្ណៈ៖ ចឹងសព្វថ្ងៃតា នួន ជា តាអៀង សារី ខៀវ សំផន គេកំពុងឃុំខ្លួននៅតុលាការខែរក្រហមណាស!

រឹម ៖ បាទ!

វណ្ណៈ៖ រង់ចាំការកាត់ទោសណាស ។ ចឹងតើពូយល់ថាការកាត់ទោសខ្មែរក្រហមនេះជាការត្រឹមត្រូវតាមច្បាប់ដែរទេ?

រឹម ៖ ពិបាកដែរខ្ញុំនៅខាងខ្មែរក្រហមកាន់ជើងខ្មែរក្រហម តែអំពើដែលខុសអំពើណាដែលត្រូវគេមើលឃើញចឹងខ្ញុំអត់ដឹងដែរ ។ ខ្ញុំអត់ដឹងខាងច្បាប់ខ្ញុំមិចអាចវិនិច្ឆ័យបានទេ កំរិតខ្ញុំត្រឹមប្រជនដឹងតែរកស៊ី ដឹងតែអត់ហើយនឹងមានប៉ុណ្ណឹងទេ ខ្ញុំអត់ដឹងទេអាហ្នឹងចឹងណាស!

វណ្ណៈ៖ បាទ!

រឹម ៖ តែបើតាមខ្ញុំខ្មែរក្រហមនឹកឃើញថា គាត់ចាស់ៗអស់ហើយមិនគួរណាកាត់ទោសគាត់ទេ បើគាត់ធ្វើខុសទៅហើយ ក្នុងមួយជីវិតមនុស្សវាមានខុសដែរការដឹកនាំ ឬមួយក៏គាត់ដឹកនាំចង់ឲ្យល្អដែរខាងក្រោមគេថាឲ្យរួចឲ្យឆៅដុតឲ្យខ្លោចចឹងក៏ថាបានចឹងក៏ថាបានវាមិនទៀងទាត់ឬក៏ច្បាប់វិនិច្ឆ័យយ៉ាងម៉េចខ្ញុំក៏មិនដឹងដែរគ្រាន់តែខ្ញុំមិនដឹងឥទ្ធិពលវាលំបាកយ៉ាងណា អត់ដឹង ថាគាត់ហ្នឹងល្អចឹងណាស ។ ខ្ញុំនិយាយតែត្រង់ៗចឹងទៅ ខ្ជិល វៀចក៏គ្មានន័យអីដែរ ឃើញត្រង់ថាត្រង់ហើយវៀចវេបានប្រយោជន៍អីទេគ្មានយកទៅឯណាទេ ។

វណ្ណៈ៖ បាទ ដូចថាបេះ បើតាមផ្លូវច្បាប់ដូចថាគាត់ជាមេដឹកនាំតែប៉ុន្មានឆ្នាំហើយស្លាប់មនុស្សអស់រាប់លាននាក់ចឹងទៅវាខុសនឹងច្បាប់អន្តរជាតិ ដូច្នេះគេគិតឃើញថាទោះបីគាត់មិនបានសមលាប់មិនបានអីមែន តែគាត់ជាម៉ែជាឪ ។ កាន់ប្រទោសមួយទាំងមូលហេតុអីក៏អត់ដឹងថាកូនចៅខ្លួនឯងអត់បាយ ហេតុអីក៏មិនដឹងថាកកូនចៅខ្លួនស្លាប់ ចឹងហើយបានគេគំរូវឲ្យមានការកាត់ទោស ។ បាទ! ចឹងអាហ្នឹងវាទៅតាមផ្លូវច្បាប់ចឹងយើងមិនដឹងដែរណាពូ ស្រេចតែលើច្បាប់ទៅចុះ ។

រឹម ៖ ក្មួយនិយាយត្រូវ អាកូនស្លាប់ម៉េចមិនប្រាប់ឲ្យមេឃុំមេភូមិដឹង អាហ្នឹងចឹងហើយណ៎?

វណ្ណៈ:   បាទ!ដូចកាលនោះវាអត់មានសារពត៌មាន កាសែត្រអី...

រីម :   អត់ ។

វណ្ណៈ:   បិតឈឹង គ្រាន់តែក្រោយមកអ្នកការសែត្រអាមេរិកកាំងមកចូលមកនៅឆ្នាំ៧៧ ចូលមកថតមកអីហ្នឹងក្រោយមកទៅដេកនៅសណ្ឋាគារនៅជិតវត្តភ្នំហ្នឹងក៏កង់ទ័ពខ្មែរក្រហមឡើងទៅសំលាប់ដែរ សំលាប់បំបិតមាត់ខ្លាចយកពត៌មានចេញទៅក្រៅ ។ អាហ្នឹងយើងមិនដឹងថាគោលការណ៍ខ្មែរក្រហមគេបំរុងធ្វើអីនៅប្រទេសកម្ពុជាទេណាស!

រីម :   បាទ!

វណ្ណៈ:   យើងមិនដឹងដែរ តែភាគច្រើនអ្នកនៅជិតគាត់ថាគាត់ល្អហើយក៏បានហូបចុកគ្រប់គ្រាន់ តែប្រជាជននៅតាមជនបទវេងគ្រោះអាហ្នឹងយើងមិនដឹងដែរសាច់រឿងពូណាស!

រីម :   បាទ!

វណ្ណៈ:   ចឹងចាំមើលតុលាការកាត់ទោសគេនឹងដឹងស ខ្មៅថាអ្នកណានៅពីក្រោយអីចឹងប្តុមួយគាត់ហ៊ាននិយាយដែរប្តុក៏អត់ ។ ចឹងកាលជំនាន់នោះពូដឹងថាសម្តេចយាងនៅក្នុងប្រទេសដែរប្តុក៏អត់?

រីម :   ពុតែគេថានៅ ពុតែគេថាដូចខ្យល់ល្ហៀកៗចឹងនោះ ពុគេថានៅក្នុងប្រទេសតែអារបៀនមិនដែលបានដើរហើរចឹងណាស!

វណ្ណៈ:   គាត់នៅឃុំឃាំង ។

រីម :   បាទ!ខ្ញុំពុតែមួយម៉ាត់ មិនសូវហ៊ាននិយាយទេ តែនិយាយទៅវាខុសហើយជំនាន់នោះ ។

វណ្ណៈ:   ពូបើគិតថាសម័យតស៊ូហើយមកដល់សម័យឥឡូវ ពូគិតមើលថាកាលនៅសម័យតស៊ូពូមិនសូវលំបាកប្តុក៏មកដល់សម័យនេះពូលំបាកជាងគិតទៅយ៉ាងម៉េចពូ?

រីម :   ទេ!កាលសតស៊ូហ្នឹងលំបាកណាស់ណា ជាងមួយរយដងឯណោះ គ្រាន់តែបាយជាងមួយរយដង...

វណ្ណៈ:   ឥឡូវសប្បាយជាងហ្អីពូ?

រីម :   បាទ!សប្បាយជាង ។

វណ្ណៈ:   ហើយកូនចៅបានរៀនសូត្រ យើងចង់រក រក ចង់ដេក ដេក?

រីម :   បាទ!អត់មានអ្នកណាបង្ខំ វ៉ៃដំអីទេ ។

វណ្ណៈ:   យើងរកបាន បើមិនរកអត់!

រីម :   បាទ!យើងប្រឹងទៅ!

វណ្ណៈ: បាទ! ចឹងពូថាសម័យឥឡូវសប្បាយជាង សម័យគស៊ូសំលាប់មនុស្សទៀត ហើយលំបាក តែហូបចុកគ្រប់គ្រាន់ទេ?

រឹម : បាទ!

វណ្ណៈ: តែក៏មានអ្នកខ្លះគេថាសម័យគស៊ូស្រួលណាស់ គេអត់ភ័យខ្លាចអីទេដឹងតែមានហូបរាល់ថ្ងៃខ្លះ គេនិយាយចឹងវិញ ។

រឹម : ចុះអាហ្នឹងគេគិតតែខ្លួនឯងអត់គិតបងប្អូនជីដូនមួយ ហើយអ្នកដទៃគ្នាលំបាកណាស់យើងគិតតែស្រួលអត់យោងអានោះផង ។

វណ្ណៈ: បាទ!ប៉ុន្តែខ្លះគិតត្រូវហើយដូចយើងមើលឃើញថាតិចទៀតមានថ្នល់ជាត់ មានភ្លើងអគ្គិសនី...

រឹម : តិចទៀតស្រួលហើយ!

វណ្ណៈ: បាទ!តិចទៀតយើងអាចទៅលេងភ្នំពេញបាន បើសម័យគស៊ូយើងនៅតែក្នុងព្រៃរហូត ដេកតែចងអង្រឹង...

រឹម : អូ....

វណ្ណៈ: មានអីស្រួលជាងពូណ៎?

រឹមៈ បាទ!

វណ្ណៈ: អានេះជាយោបល់របស់គេពូណ៎?

រឹមៈ បាទ!

វណ្ណៈ: ចឹងពូខ្ញុំអគុណពូច្រើនណាសពូណាស?

រឹមៈ បាទ!

ចប់